Washington State Health Care Authority

Washington State Department of Social & Health Services
Transforming lives

# សិទ្ធិ និងពេលកំណត់សវនាការរដ្ឋបាលសុខភាពអេបផលរដ្ឋវ៉ាស៊ីងតោន

អ្នកមានសិទ្ធិប្តឹងសវនាការរដ្ឋបាល បើអ្នកមិនយល់ព្រមជាមួយការសម្រេចរបស់យើង ដែលបានបដិសេធ បញ្ចប់ ឬផ្លាស់ប្តូរការធានារ៉ាប់រងសុខភាពអេបផលរដ្ឋវ៉ាស៊ីងតោនរបស់អ្នក ។

- អ្នកមានពេល 90 ថ្ងៃពីកាលបរិច្ឆេទដែលមាននៅខាងលើសេចក្តីណែនាំនេះក្នុងការស្នើសុំសវនាការ ។ បើអ្នកមិនស្នើសុំសវនាការក្នុងរយៈពេល 90 ថ្ងៃទេ អ្នកអាចបាត់បង់សិទ្ធិប្តឹងសវនាការ ។
- បើអ្នកចង់រក្សាការធានារ៉ាប់រងរបស់អ្នកក្នុងអំឡុងពេលដំណើរការសវនាការ សូមមើល **ការបន្តធានារ៉ាប់រងក្នុងដំណើរការសវនាការរដ្ឋបាល**ខាងក្រោម ។
- អ្នកអាចមើលបទបញ្ញត្តិសវនាការក្នុងក្រមរដ្ឋបាលរដ្ឋវ៉ាស៊ីងតោន ជំពូក 182-526 ។
- អ្នកអាចមិនមានសិទ្ធិប្តឹងសវនាការ បើការធានារ៉ាប់រងរបស់អ្នកត្រូវបានបដិសេធ បញ្ចប់ ឬផ្លាស់ប្តូរ ពីព្រោះមានការផ្លាស់ប្តូរច្បាប់រដ្ឋ ឬសហព័ន្ធ ហើយវាប៉ះពាល់ជាស្វ័យប្រវត្តិដល់អ្នកចុះឈ្មោះក្នុងកម្មវិធីដូចៗគ្នា (RCW 74.09.741(3)) ។

បើអ្នកមានប្រាក់ចំណូលតិច យោបល់អប់រំផ្នែកច្បាប់ដែលមានការសម្របសម្រួល និងការបញ្ជូនទៅ អាចជួយអ្នកស្វែងរកជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ។ អ្នកអាចដាក់ពាក្យនៅ http://nwjustice.org/clear-online ឬ ៖

- បើអ្នកមានអាយុក្រោម 60 ឆ្នាំ ហៅទូរស័ព្ទមកយោបល់អប់រំផ្នែកច្បាប់ដែលមានការសម្របសម្រួល និងការបញ្ជូនទៅ តាមលេខ 1-888-201-1014 ។
- បើអ្នកមានអាយុលើសពី 60 ឆ្នាំ ហៅទូរស័ព្ទមកយោបល់អប់រំផ្នែកច្បាប់ដែលមានការសម្របសម្រួល និងការបញ្ជូនទៅផ្នែកមនុស្សចាស់ តាមលេខ 1-888-387-7111 ។

## ការបន្តធានារ៉ាប់រងក្នុងដំណើរការសវនាការ

- អ្នកអាចរក្សាការធានារ៉ាប់រងរបស់អ្នកក្នុងអំឡុងពេលដំណើរ ការសវនាការ ប្រសិនបើសេចក្តីជំណឹងរបស់និយាយថា យើងនឹងបញ្ចប់ ឬផ្លាស់ប្តូរការធានារ៉ាប់រងសុខភាពអេបផលរដ្ឋវ៉ាស៊ីងតោនរបស់អ្នក ឬ វានិយាយថា យើងនឹងលុបចោល ពន្យាពេល ឬកាត់បន្ថយសេវាដែលបានអនុញ្ញាតពីមុនរបស់អ្នក។
- ដើម្បីរក្សាការធានារ៉ាប់រងរបស់អ្នក អ្នកត្រូវតែស្នើសុំសវនាការ មុនកាលបរិច្ឆេទធានារ៉ាប់រង ឬសេវាកម្មរបស់អ្នកត្រូវបានកំណត់ឱ្យបញ្ចប់ ឬក្នុងរយៈពេល 10 ថ្ងៃតាមប្រតិទិន ពីកាលបរិច្ឆេទដែលអ្នកបានទទួលសេចក្តីជូនដំណឹងនេះ។ យើងពិចារណាលើសេចក្តីជូនដំណឹងដែលបានទទួលក្នុងរយៈពេល 5 ថ្ងៃបន្ទាប់កាលបរិច្ឆេទលើសេចក្តីជូនដំណឹងនេះ លុះត្រាតែអ្នកបង្ហាញយើងថា អ្នកមិនបានទទួលវាក្នុងរយៈពេល 5 ថ្ងៃ ឡើយ។ដែលមានរយៈពេលយូរជាង ។
- បើអ្នកទទួលការបន្តធានារ៉ាប់រង ឬសេវាកម្ម ហើយចាញ់សវនាការ អ្នកអាចនឹងត្រូវសងប្រាក់មកវិញដល់ 60 ថ្ងៃនៃការបន្តធានារ៉ាប់រង ឬសេវាកម្ម ។
- អ្នកមិនអាចទទួលបានការធានារ៉ាប់រង ពេលដែលកំពុងរង់ចាំសវនាការក្នុងការដេញដោលការបដិសេធនៃសំណុំបែបបទសុខភាពអេបផលរដ្ឋវ៉ាស៊ីងតោនរបស់អ្នក ។

## សំណើសវនាការរដ្ឋបាល

ដើម្បីស្នើសុំសវនាការរដ្ឋបាល ឬបើអ្នកចង់បានអ្នកបកប្រែ ឬជំនួយផ្សេងៗក្នុងការស្នើសុំសវនាការ សូមធ្វើតាមចំណុចខាងក្រោម ៖

- ទូរស័ព្ទមក 1-877-501-2233 ឬការិយាល័យសេវាកម្មផ្ទះមូលដ្ឋាន និងសហគមន៍របស់អ្នក ។
- ទូរស័ព្ទមក 1-855-873-0642 ឬការិយាល័យរដ្ឋបាលការអភិវឌ្ឍន៍ពិការភាពមូលដ្ឋានរបស់អ្នក ។
- សរសេរសំបុត្រស្នើសុំសវនាការ ឬបំពេញបែបបទស្នើសុំសវនាការរដ្ឋបាល HCA 12-507 (ដែលមាននៅ http://www.hca.wa.gov/medicaid/forms) និង
  - ទូរសារមក 1-888-338-7410 ឬ
  - ផ្ញើសំបុត្រមក ៖ CSD Customer Service Center<br>PO Box 11699<br>Tacoma, WA 98411-6699

ពួកយើងនឹងពិនិត្យមើលសំណុំរឿងរបស់អ្នក និងព្យាយាមទាក់ទងអ្នកដើម្បីដោះស្រាយបញ្ហាមុនពេលសវនាការ ។